**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**អគ្គលេខាធិការដ្ឋាន**

**លេខ** ០៨/២០១៧ **អ.កបធ** សណា

# សេចក្តីជូនដំណឹង
## ស្តីពីការប្រឡងជ្រើសរើសមន្ត្រីរាជការ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ សូមជូនដំណឹងដល់បេក្ខជនទាំងពីរភេទ ដែលមានសញ្ជាតិខ្មែរ និងមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងឱ្យបានជ្រាបថា  អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញត្រូវការជ្រើសរើសបេក្ខជនជានិស្សិតទាំងពីរភេទចំនួន១៨នាក់ ដើម្បីចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់ក្របខណ្ឌអភិបាល (ប្រភេទ **ក**) លើមុខជំនាញ ៖

| | |
|---|---|
| ១- នីតិសាស្ត្រ | ចំនួន ០៩នាក់ |
| ២- គណនេយ្យ | ចំនួន ០២នាក់ |
| ៣- ព័ត៌មានវិទ្យា | ចំនួន ០២នាក់ |
| ៤- ភាសាអង់គ្លេស | ចំនួន ០៣នាក់ |
| ៥- ភាសាបារាំង | ចំនួន ០២នាក់ |

-លក្ខខណ្ឌអាយុ៖ យោងតាមមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.តត ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៧ ស្តីពីការលើកលែងលក្ខខណ្ឌអាយុ និងការកំណត់អាយុបេក្ខជនចូលរួមប្រឡងប្រជែងជ្រើសរើសចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល ដូចខាងក្រោម៖

+ បេក្ខជនដែលមានសញ្ញាបត្របណ្ឌិត ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
+ បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ
+ បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រ ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ
+ បេក្ខជនជាមន្ត្រីរាជការ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ។

-កាលបរិច្ឆេទទទួលពាក្យ៖ ចាប់ពីថ្ងៃ ២៥ ខែ មករា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៧ (រៀងរាល់ម៉ោងធ្វើការ) នៅការិយាល័យរដ្ឋបាល នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានទីតាំងនៅអាគារ "**ស**" ក្នុងវិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-កាលបរិច្ឆេទ និងមណ្ឌលប្រឡង៖ ជូនដំណឹងពេលក្រោយ។

សម្រាប់ព័ត៌មានលំអិតស្តីពីការប្រឡងនេះសូមចូលមើលគេហទំព័រ www.ccc.gov.kh

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧

លេខទូរស័ព្ទទំនាក់ទំនង៖

-០១២ ៦៧៧ ១៨៨
-០៩២ ៦៨១ ១៥២
-០១២ ៥៨៧ ៤៧០
-០១២ ២០៤ ៧៥២